01030528

E317/1

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 16 / 10 / 2014
ម៉ោង (Time/Heure) : 14:40
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សាធារណៈ / Public

## អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤

**ជូនចំពោះ៖** ការិយាល័យរដ្ឋបាល និងភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក /លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** សំណើរបស់មេធាវីការពារក្តី ខៀវ សំផន សុំឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ដល់ការិយាល័យរដ្ឋបាលឲ្យពង្រឹងសមត្ថភាពរបស់អង្គភាពបកប្រែភាសាជាបន្ទាន់

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើពីមេធាវីការពារក្តី ខៀវ សំផន សុំឱ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ទៅការិយាល័យរដ្ឋបាលឱ្យពង្រឹងសមត្ថភាពអង្គភាពបកប្រែភាសា និងបង្គាប់ឱ្យអង្គភាពបកប្រែភាសាឆ្លើយតបទៅនឹងសំណើពីពេលមុន និងនាពេលអនាគតទាំងអស់ឱ្យបានលឿនអាចធ្វើទៅបាន (ឯកសារ E317)។ មេធាវីការពារបានលើកឡើងថា អង្គភាពបកប្រែភាសាបច្ចុប្បន្ននេះមិនមានលទ្ធភាពដើម្បីធ្វើការបកប្រែសំណើបកប្រែជាច្រើនដែលមេធាវីបានបញ្ជូនទៅអង្គភាពនេះទេ ហើយមេធាវីព្យាករថា ស្ថានភាពនេះនឹងកាន់តែមានភាពយ៉ាប់យ៉ឺនថែមទៀត ដោយសារតែបច្ចុប្បន្នមេធាវីកំពុងតែរៀបចំពាក្យបណ្តឹងសាទុក្ខរបស់ខ្លួននោះ។ មេធាវីការពារក្តីស្នើឡើងថា ត្រូវដោះស្រាយបញ្ហានេះ ដើម្បីកុំឱ្យប៉ះពាល់ដល់លទ្ធភាពរបស់ អ.វ.ត.ក ក្នុងការចេញសាលក្រមក្នុងរយៈពេលសមស្រប។

២. អង្គជំនុំជម្រះកត់សម្គាល់ថា អង្គភាពបកប្រែភាសា និងសេវាកម្មដែលអង្គភាពនេះផ្តល់ជូន គឺស្ថិតនៅ

ក្រោមការទទួលខុសត្រូវរបស់ការិយាល័យរដ្ឋបាល។ ហេតុដូច្នេះ គឺការិយាល័យរដ្ឋបាល មិនមែនអង្គជំនុំជម្រះទេ ដែលត្រូវធានាថា ធនធាននៅក្នុងអង្គភាពបកប្រែមានចំនួនគ្រប់គ្រាន់ដើម្បីឆ្លើយតបនឹងតម្រូវការរបស់អង្គជំនុំជម្រះ និងភាគីពាក់ព័ន្ធទាំងអស់ និងត្រូវសម្រេចទៅលើការប្រើប្រាស់ធនធាននេះឲ្យបានត្រឹមត្រូវ ជាពិសេសក្នុងស្ថានភាពដែលថា ធនធានទាំងនេះត្រូវបានបែងចែកទៅសំណុំរឿងផ្សេងៗដើម្បីជាប្រយោជន៍នៃអង្គជំនុំជម្រះ និងភាគីនានានោះ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងបង្គាប់ការិយាល័យរដ្ឋបាលដោះស្រាយលើបញ្ហាដែលមេធាវីការពារក្តី ខៀវ សំផន បានលើកឡើងនៅក្នុងសំណើរបស់ខ្លួនឲ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន។ លើសពីនេះទៀត អង្គជំនុំជម្រះបង្គាប់ឲ្យការិយាល័យរដ្ឋបាលធានាថា អង្គភាពបកប្រែភាសាមានធនធានចាំបាច់គ្រប់គ្រាន់ដើម្បីអាចឲ្យអង្គជំនុំជម្រះ និងភាគី បំពេញភារកិច្ចរបស់ខ្លួន និងទប់ស្កាត់មិនឲ្យមានការពន្យារពេលមិនចាំបាច់នៅក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២។

៣. ឯកសារនេះគឺជាការឆ្លើយតបជាផ្លូវការរបស់អង្គជំនុំជម្រះចំពោះសំណើ E317។